ព្រះគម្ពីរសម្រាប់កុមារ
សូមបង្ហាញជូន



# ស្ថានសួគ៌
# ដែលជាទីស្ថានដ៏ស្រស់ស្អាតរបស់ព្រះ

និពន្ធដោយ: Edward Hughes

ធ្វើការពន្យល់ដោយ: Lazarus

កែសម្រួលដោយ: Sarah S.

បកប្រែដោយ: Christian Lingua

ផលិតដោយ: Bible for Children
www.M1914.org

©2018 Bible for Children, Inc.
អាជ្ញាប័ណ្ណ៖ អ្នកមានសិទ្ធិក្នុងការចម្លង ឬបោះពុម្ពរឿងនេះបាន
ដរាបណាអ្នកមិនយកទៅលក់។

នៅពេលដែលព្រះយេស៊ូវមានព្រះជន្មគង់នៅលើផែនដីនេះ
នៅឡើយ ទ្រង់បានប្រាប់ដល់
ពួកសិស្សរបស់ទ្រង់អំពីស្ថានសួគ៌។
ទ្រង់បានហៅទីនោះថា
“ដំណាក់នៃព្រះវរបិតាខ្ញុំ”
ហើយក៏បន្ទូលថា
នៅទីនោះមានលំនៅ
ជាច្រើន។ លំនៅ
គឺជាវិមានដ៏ធំ
និងស្រស់ស្អាត



ជាងអស់ទាំងវិមាននៅផែនដីនេះទៅទៀត។

ព្រះយេស៊ូវមានបន្ទូលថា “ខ្ញុំទៅរៀបកន្លែងឲ្យអ្នករាល់គ្នា បើ ខ្ញុំទៅរៀបកន្លែងឲ្យអ្នករាល់គ្នា នោះខ្ញុំនឹងត្រឡប់មកវិញ នឹងទទួលអ្នករាល់គ្នាទៅឯខ្ញុំ។” ព្រះយេស៊ូវពិតជាបានយាង នៅស្ថានសួគ៌មែន ក្រោយពេលដែលទ្រង់បានរស់ពីសុគត ឡើងវិញ។



ខណៈពេលដែលពួកសិស្សរបស់ទ្រង់បានមើលឃើញទ្រង់នៅ
ឡើយ នោះព្រះយេស៊ូវក៏បានយាងឡើងទៅស្ថានសួគ៌វិញ
ហើយមានពពកមួយចាំទទួលទ្រង់
ផុតពីភ្នែករបស់ពួកគេទៅ។



ចាប់តាំងពីពេលនោះមក
ពួកគ្រីស្ទាននៅតែនឹកចាំពួកសេច
ក្តីសន្យារបស់ព្រះយេស៊ូវថា
ទ្រង់នឹងយាងត្រឡប់មកវិញ
ដើម្បីទទួលពួកគាត់។



ព្រះយេស៊ូវមានបន្ទូលថា ទ្រង់នឹងយាងត្រឡប់មកវិញ
ជាមួយរំពេច គឺដោយគ្មានអ្នកណាម្នាក់នឹងស្មានដល់ឡើយ។
ព្រះគម្ពីរចែងថា ពួកអ្នកជឿនឹងទៅនៅជាមួយ
នឹងព្រះយេស៊ូវភ្លាមតែម្តង។
ការបាត់វត្តមានពីរូបកាយនេះ
គឺមានន័យថានឹងមានវត្តមានឡើង
វិញនៅជាមួយព្រះអម្ចាស់វិញ។



ព្រះគម្ពីរ វិវរណៈ ដែលជាកណ្ឌគម្ពីរចុងក្រោយនៃព្រះគម្ពីរ
បរិសុទ្ធ ប្រាប់យើងថាតើស្ថានសួគ៌ស្រស់ស្អាតយ៉ាងណា។
អ្វីដែលអស្ចារ្យ និងពិសេសបំផុតនោះគឺថា ស្ថានសួគ៌គឺជា
ដំណាក់របស់ព្រះ។ ព្រះគង់នៅគ្រប់ទីកន្លែង ប៉ុន្តែ
បល្ល័ង្ករបស់ទ្រង់គឺនៅស្ថានសួគ៌។



ពួកទេវតា និងពួកពលបរិវារដែលនៅស្ថានសួគ៌
ថ្វាយបង្គំព្រះនៅទីនោះ។
អស់ទាំងរាស្ត្ររបស់ទ្រង់
ដែលបានស្លាប់ទៅ
ហើយបានទៅស្ថានសួគ៌
ក៏ថ្វាយបង្គំទ្រង់ផងដែរ។



នេះគឺជាពាក្យខ្លះដែលដកស្រង់ចេញពីបទចំរៀងមួយ ដែល
ពួកអ្នកនៅស្ថានសួគ៌ច្រៀង : ទ្រង់បានលោះយើងរាល់គ្នា
ដោយព្រះលោហិតទ្រង់ ចេញពីគ្រប់ទាំ
ងពូជមនុស្ស គ្រប់ភាសា
គ្រប់នគរ ហើយពីគ្រប់ទាំងសាសន៍
ថ្វាយដល់ព្រះ ក៏តាំងយើងរាល់គ្នាឡើ
ងជានគរ
ហើយជាពួកស
ង្ឃ ថ្វាយដល់ព្រះ
នៃយើងរាល់គ្នា។
(វិវរណៈ ៥:៩)



ទំព័រចុងក្រោយនៃព្រះគម្ពីរបរិសុទ្ធពណ៌នាថាស្ថានសួគ៌គឺជា "ទីក្រុងយេរូសាឡិមថ្មី"។ នោះគឺជាទីកន្លែងដែលធំក្រៃលែង ដែលមានកំផែងយ៉ាងខ្ពស់ផងដែរ។ កំផែងត្រូវបានសង់ពី ត្បូងមណីជោតិ និងកែវមរកតដ៏ថ្លា។



មានមាស និងត្បូងមានតម្លៃជាច្រើន ស្រោបលើគ្រឹះកំផែង
រំលេចទៅដោយពណ៌ភ្លឺផ្លេកៗយ៉ាងអស្ចារ្យ។ ទ្វារនិមួយៗត្រូវ
បានធ្វើពីកែវមុក្តារមួយផ្ទាំងយ៉ាងធំ!



ទ្វារកំផែងកែវមរកតទាំងនោះមិនដែលបិទឡើយ។ តោះយើង
ចូលទៅមើលបន្តិច ...។ អស្ចារ្យណាស់! ស្ថានសួគ៌នៅផ្នែក
ខាងក្នុងស្អាតជាងខាងក្រៅទៅទៀត។ ទីក្រុងត្រូវបានធ្វើ
ឡើងពីមាសសុទ្ធ ថ្លាដូចជាកញ្ចក់។ សូម្បីតែផ្លូវក៏ត្រូវបាន
ក្រាលដោយមាសដែរ។



មានទន្លេទឹករស់ហូរចេញពីបល្ល័ង្ករបស់ព្រះ។ នៅជាប់នឹង
មាត់ទន្លេនោះមានដើមឈើជីវិត ដូចដែលឃើញមាននៅ
ក្នុងសួនច្បារអេដែនដែរ។ ដើមឈើនេះពិសេសណាស់។ វា
មានផ្លែចំនួនដប់ពីរប្រភេទខុសៗគ្នា អាស្រ័យទៅតាមខែ
នីមួយៗខុសគ្នា។ ហើយ ស្លឹកនៃដើមជីវិតនោះក៏សម្រាប់
ប្រោសឲ្យមនុស្សគ្រប់ជាតិសាសន៍បានផង។



ស្ថានសួគ៌មិនត្រូវការពន្លឺព្រះអាទិត្យ ឬព្រះច័ន្ទឡើយ។
សិរីល្អរបស់ព្រះបំភ្លឺទីនោះដោយរស្មីពន្លឺដ៏អស្ចារ្យ។
នោះទីនោះក៏មិនដែលមានយប់ដែរ។



សូម្បីតែសត្វនៅស្ថានសួគ៌ក៏ខុសប្លែកពីផែនដីនេះដែរ។ ពួកវាទាំងអស់សុទ្ធតែស្លូតៗ ហើយរាក់ទាក់ទៀតផង។ សត្វស្វាន និងចៀម ស៊ីស្មៅជាមួយគ្នា។ ទោះបីជាសត្វសិង្ហដ៏ខ្លាំងពូកែ ក៏ស៊ីស្មៅដូចជាសត្វគោដែរ។ ព្រះអម្ចាស់មានបន្ទូលថា “វាក៏នឹងមិនធ្វើឲ្យខូចខាត ហើយក៏នឹងមិនបំផ្លាញដល់ភ្នំបរិសុទ្ធរបស់អញឡើយ។”



កាលយើងសម្លឹងមើលជុំវិញ នោះយើងកត់សំគាល់ឃើញថា
មានការមួយចំនួនដែលឥតមាននៅក្នុងស្ថានសួគ៌ឡើយ។
ឥតដែលឮពាក្យកំហឹងណាឡើយ។ ឥតមានមនុស្សឈ្លោះ
ប្រកែកគ្នា
ឬក៏អាត្មានិយម
ទៀតទេ។



ឥតមានសោរចាក់ទ្វារទៀត ព្រោះនៅស្ថានសួគ៌ឥតមាន
ចោរសោះឡើយ។ ឥតមានមនុស្សកុហក ក៏ឥតមានឃាតករ
ឬគ្រូធ្មប់អាប ហើយក៏ឥតមានមនុស្សអាក្រក់ដែរ។ ឥត
មានអំពើបាបណា
នៅស្ថានសួគ៌
ទៀតឡើយ។





នៅស្ថានសួគ៌ជាមួយព្រះ
នឹងលែងមានទឹកភ្នែក
ទៀតហើយ។ ពេលខ្លះ រាស្ត្រ
របស់ព្រះយំសោក ព្រោះតែ
មានទុក្ខព្រួយច្រើនពេក
នៅក្នុងជីវិតនេះ។ នៅស្ថាន
សួគ៌ ព្រះទ្រង់នឹងជូតអស់
ទាំងទឹកភ្នែកចេញ។

នៅស្ថានសួគ៌ លែងមានសេចក្ដីស្លាប់ទៀតដែរ។ រាស្ត្ររបស់ព្រះនឹងបាននៅជាមួយព្រះអម្ចាស់ជារៀងរហូតតទៅ។ ក៏នឹងលែងមានសេចក្ដីទុក្ខព្រួយ សេចក្ដីយំសោក និងសេចក្ដីឈឺចាប់ទៀតដែរ។ លែងមានជំងឺ លែងមានការបែកបាក់ ហើយក៏លែងមានបុណ្យសពដែរ។ គ្រប់គ្នានៅស្ថានសួគ៌សុទ្ធតែបានអរសប្បាយជារៀងរាបដរាបជាមួយព្រះ។



ពិសេសលើសនោះទៅទៀត ស្ថានសួគ៌គឺសម្រាប់កូនក្មេង ទាំងប្រុសទាំងស្រី (ហើយសម្រាប់ទាំងមនុស្សធំ) ទាំងឡាយ ណាដែលបានជឿព្រះយេស៊ូវគ្រីស្ទ ទុកជាព្រះអង្គសង្គ្រោះ ហើយក៏បានស្តាប់បង្គាប់ទ្រង់ ទុកជាព្រះអម្ចាស់សម្រាប់ ជីវិតផ្ទាល់ខ្លួនផងដែរ។



នៅស្ថានសួគ៌មានសៀវភៅមួយហៅថា បញ្ជីជីវិតរបស់កូនចៀម។ បញ្ជីនោះមានពេញសុទ្ធតែឈ្មោះរបស់មនុស្ស។ តើអ្នកដឹងទេថា មានឈ្មោះនរណាខ្លះដែលត្រូវបានកត់ចុះក្នុងនោះ? គឺ មនុស្សទាំងអស់ដែលបានដាក់សេចក្តីជំនឿទុកចិត្តលើព្រះយេស៊ូវ។

តើឈ្មោះរបស់អ្នកមាន
នៅក្នុងនោះទេ?



ពាក្យចុងក្រោយបង្អស់របស់ព្រះគម្ពីរបរិសុទ្ធអំពីស្ថានសួគ៌
គឺជាការអញ្ជើញយ៉ាងអស្ចារ្យមួយ។



“ព្រះវិញ្ញាណ និងប្រពន្ធថ្មោងថ្មីពោលថា ‘អញ្ជើញមក!’ ហើយអ្នកណាដែលឮ ក៏ថា ‘អញ្ជើញមក!’ ដែរ។ អ្នកណាដែលស្រេក នោះមានតែមក ហើយអ្នកណាដែលចង់បាន មានតែយកទឹកជីវិតនោះចុះ ឥតចេញថ្លៃទេ។”



ស្ថានសួគ៌ ដែលជាទីស្ថានដ៏ស្រស់ស្អាតរបស់ព្រះ

រឿងមួយដែលបានមកពីព្រះបន្ទូលរបស់ព្រះ
គឺជាព្រះគម្ពីរ

អាចរកឃើញនៅក្នុង

យ៉ូហាន ១៤; ២ កូរិនថូស ៥; វិវរណៈ ៤; ២១; ២២

“ការបើកសំដែងព្រះបន្ទូលទ្រង់ នោះផ្សាយពន្លឺចេញ។”
ទំនុកដំកើង ១១៩:១៣០

ចប់

រឿងព្រះគម្ពីរនេះប្រាប់យើងអំពីព្រះដ៏អស្ចារ្យរបស់យើង
ដែលបានបង្កើតយើង ហើយដែលសព្វព្រះទ័យឲ្យអ្នកស្គាល់ដល់ទ្រង់។

ព្រះអង្គជ្រាបថាយើងបានប្រព្រឹត្តអំពើអាក្រក់ ដែលទ្រង់ហៅថាជាអំពើបាប។
ទោសនៃអំពើបាបគឺជាសេចក្តីស្លាប់ ប៉ុន្តែព្រះទ្រង់ស្រឡាញ់អ្នកខ្លាំងណាស់
ទើបទ្រង់បានចាត់ព្រះរាជបុត្រាទ្រង់តែ១ ព្រះនាមថាព្រះយេស៊ូវ
ឲ្យមកសុគតនៅលើឈើឆ្កាង ហើយឲ្យរងទោសជំនួសអំពើបាបរបស់អ្នក។
បន្ទាប់មក ព្រះយេស៊ូវមានព្រះជន្មរស់ឡើងវិញ រួចទ្រង់យាងទៅស្ថានសួគ៌វិញ!
ប្រសិនបើអ្នកជឿព្រះយេស៊ូវ ហើយទូលសូមទ្រង់ឲ្យអភ័យទោសអំពើបាបរបស់អ្នក
នោះទ្រង់នឹងអត់ទោសឲ្យជាពិត! ទ្រង់ក៏នឹងយាងមក
ព្រមទាំងគង់នៅក្នុងជីវិតរបស់អ្នកឥឡូវ
ហើយអ្នកនឹងបានរស់នៅជាមួយទ្រង់ជារៀងរហូត។

ប្រសិនបើអ្នកជឿចំពោះសេចក្តីពិតនេះ នោះចូរទូលសេចក្តីនេះដល់ព្រះអង្គថា៖
ព្រះយេស៊ូវអើយ ខ្ញុំជឿថាទ្រង់គឺជាព្រះ
ដែលបានយាងមកកើតជាមនុស្សដើម្បីសុគតជំនួយអំពើបាបរបស់ខ្ញុំ
ហើយទ្រង់ក៏មានព្រះជន្មរស់ឡើងវិញរហូតដល់សព្វថ្ងៃ។
សូមយាងមកគង់ក្នុងជីវិតរបស់ខ្ញុំ ហើយសូមអភ័យទោសអំពើបាបរបស់ខ្ញុំ
ដើម្បីឲ្យខ្ញុំមានជីវិតថ្មីនាពេលឥឡូវនេះ
រហូតដល់ថ្ងៃដល់ដែលខ្ញុំអាចទៅនៅជាមួយទ្រង់ជារៀងរហូត។
សូមជួយខ្ញុំឲ្យចេះស្តាប់បង្គាប់ទ្រង់
ហើយរស់នៅសម្រាប់ទ្រង់ក្នុងនាមជាកូនរបស់ព្រះអង្គផង។ អាម៉ែន។

សូមអានព្រះគម្ពីរ ហើយសន្ទនាជាមួយព្រះរាល់ថ្ងៃ! យ៉ូហាន ៣:១៦